**ព្រឹត្តិប័ត្រសារព័ត៌មាន** **៨ មេសា ២០២៦**

# ធនាគារ មេយប៊ែង ខេមបូឌា និងក្រុមហ៊ុន ស្មាត អាស្យាតា (Smart Axiata) ជម្រុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងប្រព័ន្ធ 5G នៅប្រទេសកម្ពុជា

ធនាគារ មេយប៊ែង ខេមបូឌា បានផ្តល់កម្ចីហិរញ្ញប្បទានចំនួន ៥០លានដុល្លារអាមេរិក ដល់ក្រុមហ៊ុន ស្មាត អាស្យាតា (ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន Axiata Group Berhad មានទីស្នាក់ការកណ្តាលនៅប្រទេសម៉ាឡេស៊ី) ដើម្បីពន្លឿនការអភិវឌ្ឍជាយុទ្ធសាស្ត្រ នៃហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងទូរគមនាគមន៍របស់កម្ពុជា រួមទាំងការតភ្ជាប់បណ្តាញ 5G នៅទូទាំងប្រទេស។

ហិរញ្ញប្បទាននេះបង្ហាញឲ្យឃើញពីការប្តេជ្ញាចិត្តរួមគ្នារវាងធនាគារ មេយប៊ែង និង ក្រុមហ៊ុន ស្មាត អាស្យាតា ក្នុងការពង្រឹងមូលដ្ឋានគ្រឹះឌីជីថល ដែលជាសសរស្តម្ភទ្រទ្រង់ដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមរបស់កម្ពុជា។ ការកែលម្អហេដ្ឋារចនាសម្ព័ន្ធនេះ នឹងជួយជំរុញឲ្យមានលទ្ធភាពកាន់តែប្រសើរ ក្នុងការទទួលបានការអប់រំតាមបែបឌីជីថល និងការសិក្សាពីចម្ងាយសម្រាប់យុវជន ព្រមទាំងសេវាហិរញ្ញវត្ថុ និងការទូទាត់ និងការជួយដល់បណ្តាអាជីវកម្ម រួមទាំងសហគ្រាសធុនតូច និងមធ្យម (SMEs) ក្នុងការចាប់យកបច្ចេកវិទ្យាឌីជីថល និងដំណោះស្រាយព័ត៌មានវិទ្យា (ICT) ដើម្បីបង្កើនផលិតភាព និងពង្រីកទីផ្សាររបស់ខ្លួនឲ្យកាន់តែទូលំទូលាយ។

**លោក រ័ត្ន សោភ័ណ** នាយកប្រតិបត្តិ និងជានាយកប្រចាំប្រទេស នៃធនាគារ មេយប៊ែង ខេមបូឌា បានមានប្រសាសន៍ថា៖ « ហិរញ្ញប្បទាននេះជួយសម្រួលដល់ការអភិវឌ្ឍសហគមន៍ និងសេដ្ឋកិច្ចផ្នែកឌីជីថល ដែលស្របតាមក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ ក៏ដូចជាអាទិភាព នៃសេដ្ឋកិច្ចថ្មី និងគោលបំណងប្រកបដោយចីរភាព ROAR30 របស់ ធនាគារ មេយប៊ែង ផងដែរ។ យើងចាត់ទុកសេដ្ឋកិច្ចថ្មីនេះ គឺជាសសរស្តម្ភស្នូលនៃរបៀបវារៈជាតិរបស់កម្ពុជា ព្រមទាំងជាកម្លាំងចលករដ៏សំខាន់នៃកំណើនរបស់អាស៊ាន ដើម្បីពន្លឿនការផ្លាស់ប្តូរឆ្ពោះទៅរកវិស័យដែលមានឥទ្ធិពល និងតម្លៃខ្ពស់។ កិច្ចសហការជាមួយក្រុមហ៊ុន ស្មាត អាស្យាតា (Smart Axiata) នេះ តំណាងឲ្យហិរញ្ញប្បទានដំបូងគេបង្អស់ ដែលស្របតាមសេដ្ឋកិច្ចថ្មីក្នុងប្រទេសកម្ពុជា ដែលបញ្ជាក់កាន់តែច្បាស់ពីផែនការយុទ្ធសាស្ត្រ ROAR30 របស់សម្ព័ន្ធធនាគារ មេយប៊ែង ក្នុងការៀបចំថវិកាចំនួន ១០០ ប៊ីលានរីងហ្គីត (២៥ ប៊ីលានដុល្លារអាមេរិក) សម្រាប់គំនិតផ្តួចផ្តើមសេដ្ឋកិច្ចថ្មី និង ៣០០ ប៊ីលានរីងហ្គីត (៧៥ ប៊ីលានដុល្លារអាមេរិក) សម្រាប់ហិរញ្ញប្បទានប្រកបដោយចីរភាពត្រឹមឆ្នាំ ២០៣០។»

តាមរយៈការបន្តកិច្ចសហការនេះ ក្រុមហ៊ុន ស្មាត អាស្យាតា (Smart Axiata) កំពុងបន្តកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍបណ្តាញរបស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងតម្រូវការដែលកំពុងកើនឡើងនៅក្នុងប្រទេស សម្រាប់ការតភ្ជាប់ប្រកបដោយភាពជឿជាក់ និងត្រៀមខ្លួនរួចជាស្រេចសម្រាប់ពេលអនាគត។

លោក **Ritesh Kumar Singh** នាយកប្រតិបត្តិរបស់ក្រុមហ៊ុន ស្មាត អាស្យាតា (Smart Axiata) បានមានប្រសាសន៍ថា៖ «ការតភ្ជាប់គឺជាស្នូលនូវរាល់សកម្មភាព ដែលយើងធ្វើ។ វាគឺជាវិធី ដែលអាចជួយសម្រួលដល់ជីវភាពរស់នៅរបស់ប្រជាជន និងគាំទ្រដល់កំណើនរយៈពេលវែងនៅកម្ពុជា។ ហិរញ្ញប្បទានពីធនាគារ មេយប៊ែង ខេមបូឌានេះ អនុញ្ញាតឲ្យយើងព

ន្សឿនការវិនិយោគលើបណ្ដាញ 5G និងហេដ្ឋារចនាសម្ព័ន្ធឌីជីថល ព្រមទាំងពង្រីកលទ្ធភាពទទួលបានសេវាកម្ម ដើម្បីឲ្យប្រជាជនកម្ពុជាកាន់តែច្រើនអាចសិក្សារៀនសូត្រ បំពេញការងារ និងរីកចម្រើនទៅមុខ។ ស្របតាមអាទិភាពជាតិ យើងមានគោលដៅនាំយកសេវាអ៊ីនធឺណិតជំនាន់ថ្មីជូនដល់ប្រជាជនកម្ពុជាគ្រប់រូប ដើម្បីបើកឱកាសសម្រាប់បុគ្គល អាជីវកម្ម និងសេដ្ឋកិច្ចឆ្ពោះទៅរកភាពរីកចម្រើននៅក្នុងយុគសម័យឌីជីថល តាមរយៈហេដ្ឋារចនាសម្ព័ន្ធ ដែលត្រៀមរួចជាស្រេចសម្រាប់ពេលអនាគត ព្រមទាំងជួយពង្រឹងប្រព័ន្ធឌីជីថលផងដែរ។»

លោក **Dato' John Chong Eng Chuan** នាយកប្រតិបត្តិសម្ព័ន្ធ នៃផ្នែកធនាគារសកល នៃធនាគារ មេយប៊ែង បានមានប្រសាសន៍ថា៖ «ការវិនិយោគប្រកបដោយចិរភាពលើការលើកកម្ពស់ ការតភ្ជាប់ក្នុងស្រុក នឹងជួយជម្រុញបន្ថែមលើការវិនិយោគមកកាន់ប្រទេសកម្ពុជា ការបង្កើតការងារ និងរួមចំណែកដល់សមាហរណកម្មតំបន់ដ៏សំខាន់។ ភាពជាដៃគូជាមួយក្រុមហ៊ុន ស្មាត អាស្យាតា (Smart Axiata) ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ Axiata Group Berhad នេះ បានពង្រឹងនូវសេចក្តីប្រាថ្នាដ៏ទូលំទូលាយរបស់ ធនាគារ មេយប៊ែង សម្រាប់តំបន់អាស៊ាន ក្នុងការផ្សារភ្ជាប់ទំនាក់ទំនង និងស្វែងរកឱកាសឆ្លងដែនសម្រាប់អតិថិជន ព្រមទាំងផ្ដល់នូវផលវិជ្ជមានដល់សង្គមផងដែរ។»

ធនាគារ មេយប៊ែង និង ក្រុមហ៊ុន ស្មាត អាស្យាតា (Smart Axiata) នឹងបន្តពង្រឹងកិច្ចសហការនេះឲ្យកាន់តែស៊ីជម្រៅ ដើម្បីជំរុញការអភិវឌ្ឍផ្អែកលើការតភ្ជាប់របស់កម្ពុជា និងវឌ្ឍនភាពក្នុងតំបន់អាស៊ាន។

****

## អំពីធនាគារ មេយប៊ែង ខេមបូឌា

ធនាគារ មេយប៊ែង ខេមបូឌា គឺជាគ្រឹះស្ថានហិរញ្ញវត្ថុឈានមុខគេមួយនៅក្នុងប្រទេស ដែលមានវត្តមានតាំងពីឆ្នាំ១៩៩៣។ ធនាគារនេះបានក្លាយជាធនាគារពាណិជ្ជក្នុងស្រុកនៅឆ្នាំ២០១២ ដែលបង្ហាញពីការប្តេជ្ញាចិត្តរយៈពេលវែងចំពោះការអភិវឌ្ឍសេដ្ឋកិច្ចរបស់កម្ពុជា។ ធនាគារផ្ដល់ជូននូវសេវាហិរញ្ញវត្ថុពេញលេញ រួមមានសេវាធនាគារសម្រាប់សាជីវកម្ម ពាណិជ្ជកម្ម និងអតិថិជនបុគ្គល ព្រមទាំងដំណោះស្រាយធនាគារតាមអ៊ីនធឺណិត និងទូរសព្ទដៃផងដែរ។ បច្ចុប្បន្ន ធនាគារ មេយប៊ែងមានបណ្ដាញសាខាចំនួន ២១ នៅទូទាំងរាជធានីភ្នំពេញ និងបណ្ដាខេត្តសំខាន់ៗទូទាំងប្រទេស។

ធនាគារ មេយប៊ែង ខេមបូឌា គឺជាផ្នែកមួយនៃសម្ព័ន្ធធនាគារ មេយប៊ែង ដែលជាសម្ព័ន្ធសេវាកម្មហិរញ្ញវត្ថុឈានមុខគេក្នុងតំបន់អាស៊ាន ដោយផ្តល់សេវាធនាគារ ធនាគារវិនិយោគ ធនាគារឥស្លាម ការធានារ៉ាប់រង និងសេវាគ្រប់គ្រងទ្រព្យសម្បត្តិ។ ជាមួយនឹងវត្តមានក្នុងបណ្តា ១៨ប្រទេស រួមទាំងទីផ្សារអាស៊ានទាំង១០ និងមជ្ឈមណ្ឌលហិរញ្ញវត្ថុសកលសំខាន់ៗ ទីផ្សារស្នូលរបស់ធនាគារ មេយប៊ែង រួមមាន ប្រទេសម៉ាឡេស៊ី សិង្ហបុរី ឥណ្ឌូនេស៊ី និងកម្ពុជា។

## អំពីក្រុមហ៊ុន ស្មាត អាស្យាតា (Smart Axiata)

ក្រុមហ៊ុន ស្មាត អាស្យាតា (Smart Axiata) ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ Axiata Group Berhad (ម៉ាឡេស៊ី) គឺជាអ្នកផ្តល់ដំណោះស្រាយទូរគមនាគមន៍ឌីជីថល និងព័ត៌មានវិទ្យា (ICT) ដែលផ្តល់នូវការតភ្ជាប់បណ្ដាញ 5G ដ៏ធំទូលាយ និងសេវាកម្មឌីជីថលចម្រុះនៅទូទាំងប្រទេសកម្ពុជា ដោយបម្រើអតិថិជនជិត ៨លាននាក់។ ក្នុងនាមជាម៉ាកសញ្ញាបច្ចេកវិទ្យា និងទូរសព្ទចល័តដ៏ទូលំទូលាយ ស្មាត (Smart) កំពុងជំរុញអនាគតឌីជីថលនៅកម្ពុជា តាមរយៈការលើកកម្ពស់ផលិតភាព បង្កើនភាពសម្បូរបែបនៃរបៀបរស់នៅបែបឌីជីថល និងការអនុញ្ញាតឲ្យមានការចូលរួមក្នុងសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន ខ

ណៈពេលរួមបញ្ចូលចីរភាពទៅក្នុងយុទ្ធសាស្ត្ររបស់ខ្លួន តាមរយៈការពង្រីកបណ្តាញប្រកបដោយទំនួលខុសត្រូវ គំនិតផ្តួចផ្តើមបរិយាបន្នឌីជីថល ប្រសិទ្ធភាពប្រតិបត្តិការ និងនវានុវត្តន៍ជាបន្តបន្ទាប់។

ក្រោមការគាំទ្រពី Axiata Group Berhad ដែលជាសម្ព័ន្ធទូរគមនាគមន៍ឈានមុខគេមួយក្នុងតំបន់អាស៊ីអាគ្នេយ៍ និងក្រោមមូលនិធិអធិបតេយ្យ (Sovereign Wealth Fund) ក្រុមហ៊ុន ស្មាត អាស្យាតា (Smart Axiata) ប្រតិបត្តិការដោយប្រកាន់ខ្ជាប់នូវស្តង់ដារអភិបាលកិច្ចដ៏រឹងមាំ ការអនុវត្តល្អបំផុតជាអន្តរជាតិ និងផ្នត់គំនិតនៃការបង្កើតតម្លៃរយៈពេលវែង។ មូលដ្ឋានគ្រឹះដ៏រឹងមាំនេះ បានពង្រឹងការប្តេជ្ញាចិត្តរបស់ក្រុមហ៊ុនចំពោះកំណើនប្រកបដោយការទទួលខុសត្រូវ និងឥទ្ធិពលដ៏មានអត្ថន័យ ដោយរួមចំណែកដល់វឌ្ឍនភាពឌីជីថល ការរីកចម្រើននៃសង្គម និងការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាពរបស់កម្ពុជា។

**សម្ព័ន្ធធនាគារ មេយប៊ែង**
Izlyn Ramli
លេខទូរសព្ទ៖ +6019 200 0248
corporateaffairs@maybank.com

**ធនាគារ មេយប៊ែង ខេមបូឌា**
Qazreen Chan Abdullah
លេខទូរសព្ទ៖ +855 16 201234
qazreen@maybank.com

**ធនាគារ មេយប៊ែង សកល**
Noelle Lim
លេខទូរសព្ទ៖ +65 92334794
noelle.lim@maybank.com